# លក្ខខណ្ឌនិងខចែងទូទៅលើការប្រើប្រាស់គណនីធនាគារ

ការបើកគណនីធនាគាររបស់ខ្ញុំ/យើងខ្ញុំត្រូវបានអនុលោមតាមលក្ខខណ្ឌ និងខចែងដែលមាននៅទីនេះ (តទៅនេះហៅថាលក្ខខណ្ឌ និងខចែង) លក្ខខណ្ឌ និងខចែងនៃការគ្រប់គ្រងគណនីធនាគារ និងលក្ខខណ្ឌជាក់លាក់ផ្សេងទៀតនឹងមានចែងនៅក្នុងទម្រង់បែបបទ និងឬបណ្ណប្រកាសជាក់លាក់ណាមួយ ហើយខ្ញុំ/យើងខ្ញុំសូមប្រកាសពីកិច្ចព្រមព្រៀងដើម្បីគោរពទៅតាមលក្ខខណ្ឌដែលបានកំណត់ទាំងនេះ។ លក្ខខណ្ឌ និងខចែងទាំងនេះក៏អនុវត្តចំពោះគណនីអេឡិចត្រូនិចផងដែរ លុះត្រាតែមានការបញ្ជាក់ផ្សេងទៀត។

1. **និយមន័យ និងការបកស្រាយ**

ពាក្យ "គណនីធនាគារ" ឬ "រាល់គណនីធនាគារទាំងអស់" មានន័យថាគណនីនីមួយៗដែលខ្ញុំ/យើងខ្ញុំប្រើប្រាស់ជាមួយធនាគារពីគ្រាមួយទៅគ្រាមួយ ហើយប្រសិនបើមានត្រូវការពាក្យនេះ នឹងមានន័យថាគណនីណាមួយ

2. **ការដាក់ប្រាក់**

2.1. រាល់ការដាក់ប្រាក់ទាំងអស់ត្រូវអមដោយប័ណ្ណដាក់ប្រាក់ ឬទម្រង់លិខិតសមស្រមណាមួយចេញពីធនាគារ ហើយអនុទ្ទេសដែលមាននោះនិងត្រូវបានពិនិត្យយ៉ាងតឹងរឹង។

2.2. ធនាគារមិនអនុញ្ញាតឱ្យអតិថិជនដាក់ប្រាក់ចូលទៅក្នុងគណនី CNY (ចិនយ៉ន់) ជាសាច់ប្រាក់ឡើយ។

2.3. បង្កាន់ដៃលចេញដោយធនាគារចាត់ទុកថាមានសុពលភាពដរាបណាបង្កាន់ដៃនេះត្រូវបានបោះពុម្ពដោយម៉ាស៊ីន ឬទទួលស្គាល់ដោយមន្ត្រីប្រតិស្រុតរបស់ធនាគារ។ ខ្ញុំ/យើងខ្ញុំត្រូវពិនិត្យមើលអោយបានជាក់លាក់ថាសកម្មភាពទាំងនេះត្រូវបានបំពេញត្រឹមត្រូវមុនពេលចាកចេញពីបរិវេណធនាគារ។ ប្រសិនបើមានកំហុស ខ្ញុំ/យើងខ្ញុំនិងរាយការណ៍ទៅធនាគារភ្លាមៗ។

2.4. ការដាក់ប្រាក់អន្តរសាខាត្រូវបានអនុញ្ញាតដោយមានការគិតកម្រៃសេវា (ប្រសិនបើមាន) ដែលធនាគារមានឆន្ទានុសិទ្ធិកំណត់គ្រប់ពេលវេលា ហើយពីគ្រាមួយទៅគ្រាមួយ។

3. **ការដកប្រាក់**

3.1. ការដកប្រាក់ត្រូវអនុលោមតាមសមតុល្យដែលមាននៅក្នុងគណនីធនាគារ។

3.2. ការដកប្រាក់តាមម៉ាស៊ីនអេធីអឹម (ATM) ត្រូវគ្រប់គ្រងដោយលក្ខខណ្ឌ និងខចែងក្នុងការប្រើប្រាស់កាត ATM ដែលបានកំណត់ដោយធនាគារ។

3.3. ការដកប្រាក់ជាសាច់ប្រាក់យ៉ន់ មិនត្រូវបានអនុញ្ញាត ប្រសិនបើអតិថិជន ត្រូវការដក់ប្រាក់ចេញពីគណនីយ៉ន់ ត្រូវតែប្តូរទៅជាសាច់ប្រាក់ រៀល/ដុល្លារ ឬក៏ អតិថិជនត្រូវ ផ្ទេរប្រាក់ពីគណនីប្រាក់យ៉ន់ ចូលទៅក្នុងគណនីប្រាក់ រៀល ឬដុល្លារ ជាមុនដើម្បីអតិថិជនអាចដកចេញពីគណនីបាន។

3.4. ការដកប្រាក់ត្រូវដែលបង្ហាញជាភស្តុតាងនូវអត្តសញ្ញាណដែលធនាគារស្នើសុំ។

3.5. ការដកប្រាក់អន្តរសាខាត្រូវបានអនុញ្ញាតដោយមាការគិតកម្រៃសេវា (ប្រសិនបើមាន) ធនាគារមាសឆន្ទានុសិទ្ធិកំណត់គ្រប់ពេលវេលា ហើយពីគ្រាមួយទៅគ្រាមួយ។

3.6. ការដកប្រាក់ជាសាច់ប្រាក់យ៉ន់ មិនត្រូវបានអនុញ្ញាតដោយធនាគារ។

## 4. អត្រាការប្រាក់

4.1. អត្រាការប្រាក់ (ប្រសិនបើមាន) ធនាគារមានឆន្ទានុកំណត់គ្រប់ពេលវេលា ហើយពីគ្រាមួយទៅគ្រាមួយ។

4.2. ពន្ធកាត់ទុកដែលអនុវត្តទៅតាមអត្រាដែលបានកំណត់ នឹងត្រូវកាត់ទុកសម្រាប់ការទូទាត់ការប្រាក់ទាំងអស់។

## 5. ការផ្តល់សិទ្ធ និងការស្នើសុំ

5.1. ខ្ញុំ/យើងខ្ញុំ ផ្តលសិទ្ធិនិងស្នើរសុំ ធនាគារគោរពនិងអនុវត្តរាល់មូលប្បទានប័ត្រ រូបិយាណត្តិ ការបញ្ជាឲ្យបង់ប្រាក់ ឧបករណ៍ទូទាត់ចំណាយ និងលិខិតសន្យាផ្តល់តាមការកំណត់ដែលត្រូវបានចេញ ចុះហត្ថលេខា ការទទួលស្គាល់ ចារខាងខ្នង ច្បាស់លាស់ ឬធ្វើឡើងដោយក្នុងនាមខ្ញុំ/យើងខ្ញុំផ្ទាល់ ឬត្រូវបានបង់ប្រាក់ដោយធនាគារ ទោះបីជាគណនីរបស់ ខ្ញុំ/យើងខ្ញុំ ស្ថិតនៅជាឥទាន ឬក្លាយជាឥណទានវិបានរូបន៍ ឬករណីផ្សេងទៀតក៏ដោយ។

5.2. ខ្ញុំ/យើងខ្ញុំផ្តល់សិទ្ធិបន្ថែមទៀត និងស្នើរសុំឲ្យធនាគារ គោរពនិងអនុលោមទៅតាមទម្រង់ជាលាយលក្ខណ៍អក្សរណាមួយក្នុងករដកប្រាក់មួយចំនួន ឬទាំងអស់ពីគណនីរបស់ខ្ញុំ/យើងខ្ញុំនិងរាល់ អុនទ្វេសជាលាយលក្ខណ៍អក្សររបស់ខ្ញុំ/យើងខ្ញុំ ក្នុងការផ្ញើរ ការដកហូត ឬលក់មូលប្បទានប័ត្រ លិខិតកាន់កាប់ ឬឯកសារផ្សេងៗ ឬទ្រព្យសម្បត្តិនានា ឬអ្វីក៏ដោយដែលស្ថិតនៅក្រោមការនាក់កាប់របស់ធនាគារនៃគណនីរបស់ខ្ញុំ/យើងខ្ញុំ ទោះបីតាមរយៈការធានា ឬទូដែកសុវត្ថិភាព ឬតាមមធ្យោបាយផ្សេងទៀត។

## 6. កម្រៃសេវាធនាគារ

6.1. ខ្ញុំ/យើងខ្ញុំយល់ព្រមថា ធនាគារមានសិទ្ធិយកកម្រៃលើសេវាដែលធនាគារបានផ្តល់ឲ្យខ្ញុំ/យើងខ្ញុំ តាមអត្រាណាមួយដែលបានកំណត់ដោយធនាគារតាមពេលកំណត់ណាមួយ។ ការគិតកម្រៃរបស់ធនាគារនឹងមិនរាប់បញ្ចូលការជាប់ពន្ធទាំងអស់ឡើយ។ ប្រសិនបើមានការជាប់ពន្ធទាំងនោះ នឹងត្រូវទទួលខុសត្រូវដោយខ្ញុំ/យើងខ្ញុំផ្ទាល់។ ធនាគារនឹងមានសិទធិទទួលបាននូវប្រាក់ពន្ធ ឬប្រាក់ផាកពិន័យណាមួយពីខ្ញុំ/យើងខ្ញុំ ដេលតម្រូវដោយច្បាប់។

6.2. រាល់កម្រៃសេវាធនាគារ (រួមទាំងពន្ធដែលត្រូវបង់ ប្រសិនបើមាន) ដែលត្រូវដល់ពេលបង់ ត្រូវកាត់ចេញពីគណនីធនាគាររបស់ខ្ញុំ/យើងខ្ញុំ។

## 7. ការផ្លាស់ប្តូរព័ត៌មានលម្អិត

7.1. រាល់ការផ្លាស់ប្តូរអាសយដ្ឋាន ឬហត្ថលេខា ឬព័ត៌មានលម្អិតផ្សេងៗទៀតដែលបានរក្សាទុកជាមួយធនាគារត្រូវតែជូនដំណឹងទៅធនាគារជាមុនលាយលក្ខណ៍ជាអក្សរ។

7.2. រាល់ការទាក់ទងទាំងអស់រួមទាំងសេវាផ្លូវច្បាប់ផ្សេងៗណាមួយដែលបាបផ្ញើរតាមប្រៃសណីយ ឬបានទុកនៅអាសយដ្ឋានរបស់ខ្ញុំ/យើងខ្ញុំបានចុះបញ្ជីចុងក្រោយជាមួយធនាគារ ត្រូវបានចាត់ទុកថាខ្ញុំបានទទួលលិខិតនោះយ៉ាងត្រឹមត្រូវ។

## 8. ការបិទគណនី

8.1. ខ្ញុំ/យើងខ្ញុំ ទទួលស្គាល់ថាគណនីធនាគាររបស់ខ្ញុំ/យើងខ្ញុំ អាចត្រូវបិទដោយខ្ញុំ/យើងខ្ញុំបានព័ត៌មានដោយផ្ទាល់ ហើយខ្ញុំ/យើងខ្ញុំនិងគោរពតាមតម្រូវការរបស់ធនាគារ (ប្រសិនបើមាន) សម្រាប់ការបិទគណនីធនាគារ។

8.2. ធនាគាររក្សាសិទ្ធិក្នុងការៈ

8.2.1. បិទគណនីធនាគារទាំងអស់ ឬណាមួយរបស់ខ្ញុំ/យើងខ្ញុំ ដោយត្រូវបានជូនដំណឹងមុនរយៈពេល ១៤ថ្ងៃ ហើយធនាគារមានសិទ្ធិមិនបញ្ជាក់ពីមូលហេតុនៃការបិទនោះទេ។

8.2.2. បិទគណនីធនាគារណាមួយរបស់ខ្ញុំ/យើងខ្ញុំ ដែលធនាគារគិតថាមិនពេញចិត្តនូវប្រតិបត្តិការណ៍ដែលគណនីបានធ្វើ។ ធនាគារអាចនឹងកិតកម្រៃសេវាក្នុងការបិទគណនីរបស់ខ្ញុំ/យើងខ្ញុំ។

8.3. មិនមានករណីក្នុងការដកសមតុល្យទាំងអស់ចេញពីគណនីធនាគារមួយមុនគណនីនោះត្រូវបានបិទនោះទេ។

## 9. គណនីធសកម្ម/ប្រាក់ដែលមិនប្រកាសទាមទារ

9.1. រាល់គណនីដែលមិនការដក/ដាក់ប្រាក់ចំនួន ១២ខែ ឬច្រើនជាងនេះនិងត្រូវចាត់ទុកថាជាគណនីអសកម្ម។

9.2. ដើម្បីដំណើរការឡើងវិញនូវគណនីអសកម្ម ត្រូវមានការដក ឬដាក់ប្រាក់នៅក្នុងគណនីដោយតម្រូវអោយអតិថិជនទៅសាខាដើម្បីធ្វើប្រតិបត្តិការណ៍បានធម្មតាវិញ។ ការដកប្រាក់ ឬដកមូលប្បទានប័ត្រចេញពីគណនីអសកម្ម មិនត្រូវបានអនុញ្ញាតសម្រាប់សាខា។

9.3. ធនាគាររក្សាសិទ្ធិក្នុងការបិទរាល់គណនីអសកម្មទាំងអស់ដែលមានសមតុល្យសូន្យ។

9.4. នៅក្នុងករណីមរណភាព ការក្ស័យធន ឬភាពវិកលចរិកកើតឡើងមកលើខ្ញុំ/យើងខ្ញុំ សមតុល្យដែលនៅសល់ក្នុងគណនីផ្នែកឥទានរបស់ខ្ញុំ/យើងខ្ញុំអាចនឹងបងទៅឲ្យក្នុងទទួលផលដែលមានសិទ្ធិស្របច្បាប់ និងអនុលោមនៅតាមបទបញ្ញាតនៃច្បាប់ដែលពាក់ព័ន្ធ។

## 10. របាយការណ៍គណនី

10.1. របាយការណ៍សមតុល្យសម្រាប់គណនីចរន្តរបស់ខ្ញុំ/យើងខ្ញុំត្រូវបានផ្តល់ជូនម្តងក្នុងមួយខែតែប៉ុណ្ណោះ។ ឬតាមការស្នើសុំ ហើយធនាគាររក្សាសិទ្ធិក្នុងការគិតកម្រៃសេវាពីគ្រាមួយទៅគ្រាមួយ។

10.2. ខ្ញុំ/យើងខ្ញុំយល់ព្រមពិនិត្យលើរបាយការណ៍គណនីធនាគាររបស់ខ្ញុំ ដោយផ្តល់អោយខ្ញុំតាមមធ្យោបាយផ្សេងៗ ឬពិនិត្យលើប្រតិបត្តិការដែលបានធ្វើឡើងនៅលើគណនីផ្សេងទៀតក្រៅពីគណនីចរន្ត ហើយខ្ញុំ/យើងខ្ញុំនឹងជូនដំណឹងទៅធនាគារ ឬ ជូនដំណឹងពីកំហុស ភាពមិនប្រក្រតី ភាពខុសគ្នា ការទាមទារ ឥណពន្ធ ឬករណីកើតឡើងណាមួយដែលមិនបានអនុញ្ញាត ទោះបីបានធ្វើឡើង ឬចំណាយដែលកើតឡើងពីការក្លែងបន្លំ មិនមានការអនុញ្ញាត ការធ្វេសប្រហេស ឬករណីផ្សេងទៀតដោយបុគ្គលណាមួយក៏ដោយ។

10.3. ខ្ញុំ/យើងខ្ញុំយល់ព្រមផងដែលថា ប្រសិនបើខ្ញុំ/យើងខ្ញុំមិនបានផ្តល់ដំណឹង ជូនធនាគារជាលាយលក្ខណ៍អក្សរពីការមិនទទួលបាននូវរបាយការណ៍ និងមិនបានទទួលរបាយការណ៍ពីធនាគារ ឬជូនដំណឹងពីកំហុស ភាពមិនប្រក្រតី ភាពខុសគ្នា ការទាមទារ ឥណពន្ធ ឬករណីនាមួយកើតឡើងដែលមិនមានការអនុញ្ញាត ឬករណីផ្សេងទៀតដែលមាននៅក្នុងរបាយការណ៍ ក្នុងរយៈពេលល១៤ថ្ងៃ រាប់ចាប់ពីពេលថ្ងៃចេញរបាយ

ការណ៍ រាល់គណនីធនាគារ ឬកំណត់ត្រាទាំងអស់ត្រូវបានចាប់ទុកថាជា ភស្តុតាងពេញក្នុងបញ្ជីប្រតិបត្តិការនិងសមតុល្យនៅក្នុងគណនីទាំងនោះ ហើយខ្ញុំ/យើងខ្ញុំត្រូវទទួលស្គាល់ថា រាល់បញ្ហាដែលរួមបញ្ចូលនៅក្នុងរបាយការណ៍នេះពិត ជាក់លាក់ និងត្រឹមត្រូវគ្រប់យ៉ាង។ រាល់ការកែប្រែក្រោយពីនេះ គឺស្ថិតនៅក្រោមឆន្ទានុសិទ្ធិតែមួយគាត់របស់ធនាគារ។

## 11. ដែនកំណត់នៃការទទួលខុសត្រូវ

11.1. ខ្ញុំ/យើងខ្ញុំយល់ព្រមថា ធនាគារនិងមិនទទួលខុសត្រូវ ហើយខ្ញុំ/យើងខ្ញុំត្រូវផ្តល់សំណងពេញលេញជូនធនាគារ និងមិនធ្វើឲ្យធនាគារទទួលរងនូវការខូចខាត ចេញសោហ៊ុយ ឬការចំណាយផ្សេងៗដែលអាចកើតឡើងចំពោះខ្ញុំ/យើងខ្ញុំ ឬដោយធនាគារដែលទាក់ទងទៅនិងគណនីធនាគារណាមួយ ឬទាំងអស់ ឬរាល់ការអនុវត្តន៍ ដោយធនាគារនូវលិខិតតុបករណ៍ផ្សេងៗ (មិនថាជាអនុទ្វេសក្លែងបន្លំ ឬមិនមានការអនុញ្ញាត) ឬគណនីធនាគារណាមួយ ឬទាំងអស់របស់ខ្ញុំ/យើងខ្ញុំ ឬផ្នែកណាមួយដែលត្រូវបានកាត់បន្ថយ ឬបង្កដោយរដ្ឋាភិបាល ឬមន្ត្រីអជ្ញាធរបានណាមួយឡើយ។

11.2. ខ្ញុំ/យើងខ្ញុំយល់ព្រមផងដែលថា នៅពេលដែលធនាគារត្រូវទទួលកងារខូចខាត ឬបាត់បងដោយសារតែការស្នើសុំរបស់ខ្ញុំ/យើងខ្ញុំ មូលនិធិ មូលប័ត្រ និងវត្ថុដែមានតម្លៃផ្សេងទៀតរបស់ខ្ញុំ/យើងខ្ញុំដែលបានដាក់បញ្ញើរជាមួយធនាគារ (ទោះបីត្រូវបានដាក់បញ្ញើរតាមរយៈ ការដាក់ធានា ទូដែកសុវត្ថិភាព ឬក្នុងគោលបំណងពិសេសណាមួយផ្សេងទៀត) ដែលជាកម្មសិទ្ធិរបស់ ខ្ញុំ/យើងខ្ញុំហើយ វានិងក្លាយទៅជាទ្រព្យរបស់ធនាគារដោយស្វ័យប្រវត្តិ ហើយធនាគារមានសិទ្ធិរក្សាទុកមូលនិធិ មូលប័ត្រ រូបិយវត្ថុ និងវត្ថុដែលមានតម្លៃទាំងនោះ ឬផ្នែកណាមួយ ព្រមទាំងបដិសេធនូវមូលប្បទានប័ត្ររបស់ខ្ញុំ/យើងខ្ញុំ រហូតដល់ពេលដែលកាតព្វកិច្ចទាំងអស់ត្រូវបានដោះស្រាយរួចរាល់។

## 12. សិទ្ធិក្នុងការទូទាត់

12.1. ខ្ញុំ/យើងខ្ញុំយល់ព្រមថា បន្ថែមលើចំណងទូទៅ ឬសិទ្ធិប្រហាក់ប្រហែលផ្សេងទៀត ដែលធនាគារមានក្នុងនាមជាធនាគារកិ ធនាគារមានសិទ្ធិតាមផ្លូវច្បាប់ និងគ្រប់ពេលវេលាដោយពុំចាំបាច់ផ្តល់ដំណឹងជាមុន ក្នុងការដាក់បញ្ចូល ឬបង្រួមគ្នានូវរាល់គណនីធនាគារណាមួយ និងបំណុលចំពោះធនាគារ ការទូទាត់ ឬការផ្ទេរនូវចំនួនទឹកប្រាក់ដែលជាឥណទានរបស់គណនីធនាគារណាមួយ ឬទាំងអស់ដើម្បីជំរះរាល់បំណុលរបស់ខ្ញុំ/យើងខ្ញុំ ជូនធនាគារទោះបីបំណុលទាំងនេះជាបំណុលចំបង បន្ទាប់បន្សំ ចំណែកផ្ទាល់ខ្លួន ឬចំណែករួមក៏ដោយ។ លើលពីនេះ ទោះបីខ្ញុំ/យើងខ្ញុំអាចនិងមានបំណុលដែលកើតឡើងក្នុងពេលជាថាហេតុ ឬកើតឡើងនាពេលអានាគត រាល់ការទទួលខុសត្រូវរបស់ខ្ញុំ/យើងខ្ញុំក្នុងការបង់នូចំនួនទឹកប្រាក់ពីឥណទាននៅក្នុងគណនីធនាគារណាមួយរបស់ ខ្ញុំ/យើងខ្ញុំចំពោះបំណុលទាំងនោះ និងត្រូវបានពន្យាពេលរហូតដល់មានការកើតឡើងហេតុការណ៍ជាថាហេតុ ឬនៅពេលអនាគតនោះ។

## 13. មូលប្បទានប័ត្រ

13.1. មូលប្បទានប័ត្រនេះមិនអាចប្រើប្រាស់បានឡើយ លុះត្រាតែធ្វើឡើងតាមទម្រង់បែបបទដែលបានផ្តល់ឲ្យនិងបានចុះបញ្ជីសម្រាប់គោលបំណងណាមួយ។ មូលប្បទានប័ត្រអាចប្រើប្រាស់បានសម្រាប់តែការដក

ប្រាក់ចេញពីគណនីធនាគារ ដែលធនាគារកំណត់ថាជាគណនីចរន្ត ឬគណនីផ្សេងទៀតដែលធនាគារបានកំណត់ពីគ្រាមួយទៅគ្រាមួយ។ រាល់ការស្នើសុំសៀវភៅមូលប្បទានប័ត្រត្រូវតែធ្វើឡើងក្នុងទម្រង់ស្នើសុំដែលបានបោះពុម្ព ឬការស្នើសុំជាលាយលក្ខណ៍អក្សរ។

13.2. លក្ខខណ្ឌដែលបានបោះពុម្ពលើគម្របសៀវភៅមូលប្បទានប័ត្រត្រូវពិនិត្យអោយបានម៉ត់ចត់ ហើយវាក៏ជាផ្នែកដ៏សំខាន់សម្រាប់ឯកសារនេះផងដែរ។

13.3. ធនាគារមានសិទ្ធិបដិសេធ លើមូលប្បទានប័ត្រណាមួដែលមានការចុះហត្ថលេខាខុសពីគំរូហត្ថលេខាដែលបានផ្តល់ឲ្យធនាគារ ហើយផ្តល់ជាមួយ និងហេតុផលសមស្របណាមួយក្នុងការបដិសេដមូលប្បទានប័ត្រដោយគ្មានការទទួលខុសត្រូវចំពោះអតិថិជនឡើយ។

13.4. មូលប្បទានប័ត្រដែលទទួលពីការប្រមូល ប៉ន្តែមិនអាចទូទាត់បាននឹងត្រូវបញ្ជូនខ្ញុំ/យើងខ្ញុំតាមអាសយដ្ឋានដែលបានចុះបញ្ជីចុងក្រោយជាមួយធនាគារដែលជាហានិភ័យ និងការចំណាយរបស់ខ្ញុំ/យើងខ្ញុំ។

13.5. ខ្ញុំ/យើងខ្ញុំនឹងផ្តលើសំណងពេលលឹញជូនធនាគារក្នុងការខាត់បង់ដែលបានកើតឡើងចំពោះហេតុផលណាមួយដូចជា ការប្រើប្រាស់បាន ការធានាលើការចារខាងនៃមូលប្បទានប័ត្រណាមួយ ឬការមិនគិតថ្លៃសេវាលើមូលប្បទានប័ត្រណាមួយ វិក័យប័ត្រ រូបិយាណត្តិ ប័ណ្ណធានាភាគលាភ ឬឧបករណ៍ទូទាត់ផ្សេងៗ ដែលបានទូទាត់ដោយខ្ញុំ/យើងខ្ញុំសម្រាប់ការប្រូមូល និងរាល់ការធានាដែលផ្តល់ដោធនាការត្រូវបានចាត់ទុកថាបានផ្តល់អោយខ្ញុំ/យើងខ្ញុំគ្រប់ករណីទាំងអស់។

13.6. ក្នុងករណីគណនីរួម មូលប្បទានប័ត្រដែលបើកអោយម្ចាស់ណាមួយមានសិទ្ធិដាក់ចូលទៅក្នុងគណនីនោះបាន ដែលធនាគារនឹងមិនទទួលខុសត្រុវលើការខាត ឬបាត់បង់ណាមួយដែលកើតឡើងដោយការទូទាត់មូលប្បទានប័ត្រនោះឡើយ ហើយការបង់ប្រាក់បែបនេះ និងត្រូវចង់ទៅលើអ្នកកាន់រួមគ្នា និងជាច្រើនមិនថាការបង់ប្រាក់បែបនេះត្រូវបានធ្វើឡើងដោយ ចំណេះដឹងការឬឬលយក ឬសិទ្ធិអំណាចរបស់អ្នកកាន់តផ្សេងទៀតឡើយ។

13.7. រាល់ការកែប្រែលើមូលប្បទានប័ត្រត្រូវមានហត្ថលេខាពេញលេញរបស់ម្ចាស់គណនីដើម្បីបញ្ជាក់។
ធនាគារអាចបដិសេធមូលប្បទានប័ត្រដែលមិនមានការចុះហត្ថលេខាពេញលេញទៅលើការកែប្រែលើមូលប្បទានប័ត្រដៃមានឆូត "បើក" "Opened" អាចទូទត់បានតែជាសាច់ប្រាក់សុទ្ធដោយអ្នកដក ឬភ្នាក់ងាររបស់ពួកគេតែប៉ុណ្ណោះ។

13.8. អនុទ្ធេសគ្នុការបញ្ឈប់ការទូទាត់មូលប្បទានប័ត្រត្រូវជាលាយលក្ខណ៍អក្សរដែលមានទម្រង់ និងអត្ថន័យធនាគារអាចទទួលយកបាន ហើយដែលអាចមានសុពលភាពនៅពេលដែលធនាគារបានទទួលលិខិតនេះ។ ទោះជាយ៉ាងណាក៏ដោយ ធនាគារមិនទទួលខុសត្រូចចំពោះការសន្យារពេល ឬការខកខានក្នុងការអនុវត្តអនុទ្ធេសនេះឡើយ។ រាល់ការណែនាំអំពីការ បញ្ឈប់ប្រតិបត្តិការណ៍ទូទាត់ទាំងអស់ត្រូវផុតកំណត់បន្ទាប់ពីរយៈពេល ដប់ពីរ (១២)ខែគិតចាប់ពីថ្ងៃដែលមានការណែនាំ។ ធនាគាររក្សាសិទ្ធិក្នុងការគិតកម្រៃសេវាតាមការកំណត់របស់ធនាគារពីគ្រាមួយទៅគ្រាមួយសម្រាប់រៀងរាល់ថ្ងៃក្នុងការអនុវត្តអនុទ្ធេសស្តីពីការបញ្ឈប់ការទូទាត់មូលប្បទានប័ត្រ។

13.9. មូលប្បទានប័ត្រទាំងអស់នៅតែជាទ្រព្យសម្បត្តិរបស់ធនាគារ ហើយនៅពេលដែលបិទគណនីចរន្ត រាលមូលប្បទានប័ត្រដែលបានចញអោយ ខ្ញុំ/យើងតែមិនទាន់ប្រើប្រាស់ត្រូវតែប្រគល់ជូនធនាគារវិញ។

13.10. មិនគួរចរថបលខាបលើមូលបបទនប័ត្រទបទរ។

13.11. មិនគួរមានមូលប្បទានប័ត្រ ឬសៀវភៅមូលប្បទានប័ត្រ ឬសម្ភារៈស្រដៀងគ្នាទុកចោលដោយមិនមានការថែរក្សា ឬមិនបានចាក់សោរនោះទេ។

13.12. ធនាគារនឹងទូទាត់តែមួយប្បទានប័ត្រដែលបានដកនៅធនាគារដែលជាសៀវភៅមូលប្បទាប័ត្រផ្តល់ដោយធនាគារ។

13.13. ខ្ញុំ/យើងខ្ញុំ និងរក្សាសៀវភៅមូលប្បទានប័ត្រដោយសុវត្ថភាពគ្រប់ពេល ហើយនិងជូនដំណឹងបន្ទាន់ទៅកាន់ធនាគារជាលាយលក្ខណ៍អក្សរ ប្រសិនបើមូលប្បទានប័ត្រណាមួយបានបាត់បង់។

## 14. **ម៉ាស៊ីនបេឡាករដោយស្វ័យប្**រវត្ត (អេធីអឹម ឬ ATM )

14.1. សេវាកម្មអាចប្រើបានតាមរយៈម៉ាស៊ីនអេធីអឹមក្នុងម៉ោងzហើយត្រូវធ្វើការណែនាំ ឬការជូនដំណឹងផ្សេងទៀតដែលអាចត្រូវបាន កំណត់ពីពេលមួយទៅពេលមួយដោយធនាគារ។

14.2. ប្រសិនបើខ្ញុំ/យើងខ្ញុំ ប្រើប្រាស់សេវាកម្មអេធីអឹមដែលជាកម្មសិទ្ធិរបស់ស្ថាប័នផ្សេងទៀត ការប្រើបាស់សេវាកម្មនេះក៏និងត្រូវ អនុវត្តតាមលក្ខខណ្ឌដែលបានកំណត់ដោយស្ថាប័នពាក់ពន្ធ។

14.3. រាល់ការស្នើសុំផ្ទេរប្រាក់តាមម៉ាស៊ីនអេធីអឹមនិងត្រូវបានចាត់ទុកថាបញ្ចប់នៅពេលដែលប្រតិបត្តិការទទួលបានជោគជ័យ។ គណនីធនាគារពាក់ព័ន្ធរបស់ខ្ញុំ/យើងខ្ញុំនិងត្រូវបានដក ហើយគណនីរបស់អ្នកទទួលផលនិងត្រូវបានដាក់ក្នុងពេលដំណាលគ្នា។

14.4. រាល់សាច់ប្រាក់ដែលដាក់តាមរយៈម៉ាស៊ីនដាក់ប្រាក់(ស៊ីដីអឹម ឬ CDM)របស់ធនាគាត្រូវធ្វើឡើងតាមទម្រង់ដែលធនាគារបានកំណត់។ ម៉ាស៊ីនដាក់ប្រាក់ ស៊ីដីអឹម និងផ្តល់បង្កាន់ដៃសម្រាប់ការដាក់ប្រាក់។ គណនីធនាគារពាក់ព័ន្ធ និងត្រូវបានបញ្ចូលជាមួយសាច់ប្រាក់ដែលបានដាក់នៅពេលធនាគារបានផ្ទៀងផ្ទាត់រួច។

14.5. ខ្ញុំ/យើងខ្ញុំទទួលស្គាល់ថា ខ្ញុំ/យើងខ្ញុំពិតជាបានពិនិត្យថាព័ត៌មានលម្អិតនៃប្រតិបត្តិការណ៍ដែលបានបោះពុម្ពលើប័ណ្ណគឺត្រឹមត្រូវមុនពេលចាកចេញពីបរិវេណធនាគារ ឬស្ថានីយអេឡិចត្រូនិច។ បើមានកំហុសណាមួយកើតឡើងនឹងត្រូវរាយការណ៍ទៅការធនាគារជាបន្ទាន់។

14.6. ប្រតិបត្តិការណ៍របស់ ស៊ីដីអឹម គឺស្ថិតនៅក្រោមប្រធានបទដែលអាចអនុវត្តបានចំពោះលក្ខខណ្ឌទូទៅដទៃទៀតដែលបានចែងនៅទីនេះ។

## 15. **ប្រាក់បញ្ញើមានការកំណត់**

15.1. ធនាគាររក្សសិទ្ធិក្នុងការកំណត់ និងផ្លាស់ប្តូរពីគ្រាមួយនូវចំនួនអប្បបរមានៃការដាក់ប្រាក់ដើម្បី បើកគណនីប្រាក់បញ្ញើមាការកំណត់។

15.2. ពន្ធកាត់ទុកដែលត្រូវបានអនុវត្តទៅតាមអត្រាដែលបានកំណត់ទុកសម្រាប់ការទូទាត់ ការប្រាក់ទាំងអស់។

15.3. ការដកប្រាក់បញ្ញើ

15.3.1. សម្រាប់ការដកប្រាក់បញ្ញើមានកាលកំណត់មុនកាលកំណត់ និងមិនទទួលបានការប្រាក់ឡើយ។ ទោះយ៉ាងណាក៏ដោយធនាគាររក្សាសិទ្ធិក្នុងការបង់ប្រាក់ បន្ទាប់បន្សំសម្រាប់ប្រាក់បញ្ញើទាំងអស់នោះដែលបានដាក់ជាមួយធនាគារក្នុងរយៈពេលមួយដែលត្រូវបានកំណត់ដោយធនាគារពីទៅពេលមួយ។

15.3.2. សម្រាប់ការដកប្រាក់បញ្ញើនៅកាលកំណត់ ការដកប្រាក់ត្រូវអនុលោមតាមខនិងលក្ខខណ្ឌនៃប្រតិបត្តិការដែលបានផ្តល់ឲ្យធនាគារដោយខ្ញុំ/យើងខ្ញុំ។

15.4. ខ្ញុំ/យើងខ្ញុំទទួលស្គាល់ថាប្រាក់បញ្ញើមានកាលកំណត់និងត្រូវបានបន្តដោយស្វ័យប្រវត្តិនៅកាលកំណត់ដែលមានរយៈពេលដដែលក្នុងអត្រាការប្រាក់ដែលនាគារអាចកំណត់ឆន្ទានុសិទ្ធិនិងដាច់ខាងរបស់ខ្លួន បើមិនដូច្នោះទេ លុះត្រាតែមានការណែនាំផ្សេងពី ខ្ញុំនៅពេលដែលដាក់ប្រាក់បញ្ញើមានការកំណត់ ឬនៅពេលណាមួយមុនការកំណត់។

15.5. ខ្ញុំ/យើងខ្ញុំ និងរក្សាវិញ្ញបនបត្រប្រាក់បញ្ញើមានកាលកំណត់ឲ្យមានសុវត្ថិភាពគ្រប់ពេលវេលា ហើយនិងរាយការណ៍ជាលាយលក្ខណ៍អក្សរទៅធនាគារ បើមានការបាត់បង់ ការលួច ឬការខូចខាត។

15.6. ខ្ញុំ/យើងខ្ញុំយល់ព្រម និងទទួលស្គាល់ថាវិញ្ញបនបត្រប្រាក់បញ្ញើមានការកំណត់ដែលបានផ្តល់ឲ្យខ្ញុំ/យើងខ្ញុំគ្រាន់តែជាការទទួលស្គាល់អំពីការដាក់ប្រាក់បញ្ញើមានការកំណត់ហើយ នោះមិនមែនជាឯកសារប្លង់ទេ។ នៅពេលដែលប្រាក់បញ្ញើមានការកំណត់ត្រូវបានដាក់តាមរយៈមូលប្បទានប័ត្រ វិញ្ញបនប័ត្រប្រាក់បញ្ញើមានការកំណត់អាចផ្តល់អោយអាស្រ័យទៅលើការទូទាត់មូលប្បទានប័ត្រ ហើយមិនត្រូវចាត់ទុកជាការបញ្ជាក់ថាមូលប្បទានប័ត្រនោះបានទូទាត់រួចទេ។ វិញ្ញបនបត្រប្រាក់បញ្ញើច្បាប់ដើមមិនមែនជាភស្តុតាងដែលបញ្ជាក់ថាប្រាក់បញ្ញើមានការកំណត់នៅតែមានសុពលភាព ហើយវាមិនមែនជាភស្តុតាងគ្រប់គ្រាន់ដើម្បីតវ៉ានូវកំណត់ត្រានៅក្នុងប្រព័ន្ធរបស់យើង ដែលបង្ហាញថាប្រាក់បញ្ញើមានការកំណត់ត្រូវបានដករួចហើយ។

15.7. ប្រតិបត្តិការរបស់ប្រាក់បញ្ញើមានកាលកំណត់គឺ ស្ថិតនៅក្រោមប្រធានបទដែលអាចអនុវត្តចំពោះលក្ខខណ្ឌទូទៅដទៃទៀតដែលបានចែងនៅទីនេះ។

## 16. ឥណទានវិបារូបន៍

ប្រសិនបើធនាគារអនុញ្ញាតឲ្យមានឥណទានវិបារូបន៍ ការប្រាក់តាមអត្រាទូទៅរបស់ធនាគារ និងកើតឡើងភ្លាមៗ ហើយចំនួនប្រាក់ដើមនីមួយៗដែលធនាគារបានសំរេចតាមឆន្ទានុសិទ្ធិ និងត្រូវសងដោយខ្ញុំ/យើងខ្ញុំតាមការទាមទារពីធនាគាររួមជាមួយការប្រាក់ ហើយរួមបញ្ចូលកម្រៃជើងសារផ្សេងៗ ការបញ្ចុះតម្លៃ និងការគិតកម្រៃរបស់ធនាគារ (ប្រសិនបើមាន)។ អត្រាការប្រាក់ដែលអាចទទួលយកបានចំពោះឥណទានវិបារូបន៍ត្រូវបានកំណត់ដោយធនាគារពីគ្រាមួយទៅគ្រាមួយ ហើយត្រូវគិតតាមចំនួនទឹកប្រាក់ដើម សម្រាប់ពេលវេលាដែលត្រូវជំពាក់ប្រចាំថ្ងៃ ហើយប្រសិនបើការប្រាក់ឬផ្នែកណាមួយមិនបានទូទាត់បង់ជាងរៀងរាល់ខែ (នៅតែបន្តមិនសង) នៅពេលដែលការប្រាក់ដដែលនេះដល់កាល ត្រូវដាក់មូលធននិងសរុបជាមួយទឹកប្រាក់ដើមសម្រាប់ក្នុងគ្រាដែលនៅជំពាក់ហើយការប្រាក់ និងត្រូវបង្គរតាមអ្វីដែលបានផ្តល់ជូននេះ។

## 17. គណនីរួម-អនុវត្តចំពោះគណនីធនាគារដែលមានឈ្មោះរួមគ្នាពីរ ឬច្រើន

17.1. ធនាគារអាចប្រមូល និងដាក់ក្នុងគណនីរបស់ខ្ញុំ/យើងខ្ញុំចំពោះមូលប្បទានប័ត្រ និងឧបករណ៍ផ្សេងទៀតជាកម្មសិទ្ធិ ឬបើកអោយម្នាក់ក្នុងចំណោមយើងខ្ញុំ។

17.2. នៅក្នុងករណីមរណភាព ការក្ស័យធន ឬភាពវិកលចរិកកើតឡើងមកលើខ្ញុំ/យើងខ្ញុំ សមតុល្យដែលនៅសល់ក្នុងគណនីផ្នែកឥទានរបស់ខ្ញុំ/យើងខ្ញុំអាចនឹងបង់ទៅឲ្យអ្នកទទួលផលដែលមានសិទ្ធិស្របច្បាប់ (ប្រសិនបើមានតម្រូវការ) និងអននុលោមទៅតាមបទបញ្ញាតិនៃច្បាប់ដែលពាក់ព័ន្ធ។

17.3. រាល់កិច្ចព្រមព្រៀង កាតព្វកិច្ច អំណាច អាជ្ញាសិទ្ធិ និងបំណុលត្រូវចាត់ទុកជារួម។ ធនាគារនិងបំពេញកាតព្វកិច្ចរបស់ខ្លួនដោយជូនដំណឹងដល់បុគ្គលណាម្នាក់ដែលមានឈ្មោះនៅក្នុងគណនីរួមនោះ។

17.4. ម្ចាស់គណនីរួមត្រូវរួមគ្នាធានា និងធ្វើឲ្យធនាគារគ្មានគ្រោះថ្នាក់ចំពោះការខាតបង់ការទាមទារ ការស្នើសុំ ការប្តឹងតវ៉ា ការចំណាយ និងបំណុលផ្សេងៗ ហើយទោះយ៉ាងណាក៏ដោយ និងរាល់ពេលដែលកើតឡើងពីការ អនុញ្ញាតដែលចេញដោយអ្នកកាន់គណនីរួម។

17.5. ប្រតិបត្តិការណ៍នៃគណនីរួម គឺស្ថិតនៅក្រោមប្រធានបទដែលអាចអនុវត្តចំពោះលក្ខខណ្ឌទូទៅដទៃទៀតដែលបានចែងនៅទីនេះ។

## 18. ការធានា

ខ្ញុំ/យើងខ្ញុំយល់ព្រមដោយឥតលក្ខខណ្ឌថា ខ្ញុំ/យើងខ្ញុំនឹងផ្តល់សំណងពេងលេងជូនធនាគារ និងមានប្រសិទ្ធិភាពដោយមិនអោយទទួលរងនូវការខាតបង់ ការទាមទារ សកម្មភាព ការប្តឹងតវ៉ា ការស្នើសុំ ការខូចខាត និងការចំណាយ (រាប់បញ្ចូលតែមិនកំណត់ចំពោះការចំណោយផ្នែកច្បាប់) ដែលអាចកើតឡើងនៅពេលណាមួយ ឬទទួលរងដោយធនាគារទោះបីមានលក្ខណៈបែបណាក៏ដោយ និងអ្វីក៏ដោយដែលកើតឡើងទាក់ទងនឹងបញ្ហា និង/ឬការអនុវត្តនរបស់ធនាគារលើសិទ្ធិទាំងឡាយណាដែលធនាគារអាចត្រូវបានបញ្ជាក់ថាមានសិទ្ធិទទួលបានការទាក់ទង់និងគណនីធនាគាររបស់ខ្ញុំ/យើងខ្ញុំ។

19. ការបង្ហាញព័ត៌មានអតិថិជននិងទិន្នន័យផ្ទាល់ខ្លួន

19.1. ខ្ញុំ/យើងខ្ញុំយល់ព្រមនិងផ្តល់សិទ្ធិដល់ធនាគារបង្ហាញដល់បុគ្គល/នីតិបុគ្គលនូវព័ត៌មានណាមួយដែល ទាក់ទង់និងគណនីធនាគាររបស់ខ្ញុំ/យើងខ្ញុំដែលត្រូវបានអនុញ្ញាតដោយច្បាប់ ឬគោលបំណងដែលធនាគារចាតទុកថាសមហេតុផលឬចំបាច់។ ធនាគារនិងមិនទទួលខុសត្រូវចំពោះការខកខាន កំហុសឆ្គង គារពន្យារពេលឬការកែប្រែព័ត៌មានមិនត្រឹមត្រូវក្នុងការធ្វើឲ្យប្រគល់ព័ត៌មានដែលបណ្តាលមកពីខ្ញុំ/យើងខ្ញុំ។

19.2. តាមការយល់ព្រមពីខ្ញុំ/យើងខ្ញុំ យល់ព្រមថានិយោជិកធនាគារអ្នកជាក់កិច្ចសន្យាឯករាជ្យ អ្នកតំណាង ឬភ្នាក់ងារដើម្បីទាក់ទងមកខ្ញុំ/ពួកយើងពេលណានៅពេលមួយតាមរយៈការជួបផ្ទាល់ ឬការប្រាស្រ័យទាក់ទងផ្ទាល់មាត់ដោយគ្រប់មធ្យោបាយរួមមានតែមិនកំណត់ចំពោះ ការហៅទូរស័ព្ទទាក់ទងនិងការផ្សព្វផ្សាយផលិតផល ឬសេវាកម្មណាមួយលើកលែងតែមានការជំទាស់ និងការ សរសេរដោយខ្ញុំ/យើងខ្ញុំ។

## 20. ខចែង និងលក្ខខណ្ឌជាក់លាក់

20.1. ទោះបីជាលក្ខខណ្ឌគ្រប់គ្រងប្រតិបត្តិការណ៍នៃគណនីជាក់លាក់ណាមួយមានភ្ជាប់នៅក្នុងនេះ ហើយក៏មានភ្ជាប់នៅក្នុងឯកសារផ្សេងទៀត ដែលទាក់ទងនិងគណនីធនាគារ ឬមាននៅក្នុងសេចក្តីជូនដំណឹងផ្សេងទៀតក៏ដោយ ខិត្តប័ណ្ណឬការផ្សព្វផ្សាយរបស់ធនាគារដែលបញ្ជប់ពីលក្ខខណ្ឌបន្ថែមក៏ និងត្រូវយកមកអនុវត្ត ហើយក្នុងករណីដែលភាពមិនស្របគ្នានោះត្រូវយកខិត្តប័ណ្ណទាំងនោះជាគោល។

21. **គណនីភាពជាដៃគូ (អនុវត្តចំពោះគណនីដែលបានចុះឈ្មោះជាដៃគូ)**

21.1. ខ្ញុំ/យើងខ្ញុំយល់ព្រមថា និងទទួលខុសត្រូវរួមគ្នាចំពោះបំណុលទាំងអស់របស់គណនីធនាគាររបស់ខ្ញុំ/យើងខ្ញុំ។

21.2. អនុទ្ទេសដែលបានផ្តល់សម្រាប់ប្រតិបត្តិការណ៍គណនីធនាគារនៅតែមានសុពលភាពរហូតដល់ការដកហូតជាលាយលក្ខណ៍អក្សរទោះបីជាមានការផ្លាស់ប្តូររដ្ឋធម្មនុញ្ញឬឈ្មោះភាពជាដៃគូក៏ដោយហើយត្រូវអនុវត្តទោះបីជាមានការផ្លាស់ប្តូរសមាជិកភាពជាដៃគូដោយការស្លាប់ ការក្ស័យធន ការចូលនិវត្តន៍ ឬផ្សេងទៀត ឬការទទួលយកដៃគូថ្មី។

22. **ប្រឆាំងការលាងលុយកខ្វក់ ការផ្តល់ហិរញ្ញប្បទានប្រឆាំងភេរវកម្ម និងការប្រឆាំងការផ្តល់ហិរញ្ញប្បទានដល់អាវុធប្រល័យលោក**

22.1. ខ្ញុំ/យើងខ្ញុំ សូមធានាថារាល់គណនីធនាគាររបស់យើងខ្ញុំ ត្រូវតែដំណើរការដោយគោរពទៅតាមច្បាប់ស្តីពីការប្រឆាំងការលាងលុយកខ្វក់ និងការប្រយុទ្ធប្រឆាំងការផ្តល់ហិរញ្ញប្បទានភេរវកម្ម និងច្បាប់ស្តីពីការប្រឆាំងការផ្តលើហិរញ្ញប្បទាននៃការរីករាយដាលនៃអាវុធប្រល័យលោក។

22.2. ទាក់ទងនិងគណនីអ្នកទទួលខុសត្រូវ/អ្នកទទួលផល/អ្នកតំណាងដែលខ្ញុំ/យើងខ្ញុំបានបើកនិង/រក្សាជាមួយធនាគារ ខ្ញុំ/យើងខ្ញុំសូមធានាបានថា ខ្ញុំ/យើងខ្ញុំបានដឹង និងបានផ្ទៀវផ្ទាត់អត្តសញ្ញាណពិតរបស់អ្នកទទួលផលរបស់ខ្ញុំ/យើងខ្ញុំ និងប្រភពទ្រព្យរបស់ពួកគេតម្រូវអោយស្ថិតនៅក្រោមច្បាប់ប្រឆាំងការលាងលុយកខ្វក់ និងហិរញ្ញប្បទានប្រឆាំងអំពីភេរវកម្មឆ្នាំ២០០១។ ខ្ញុំ/យើងខ្ញុំនិងអនុវត្តលិខិតធានាប្រសិនបើធនាគារស្នើសុំ។

23. **ច្បាប់គ្រប់គ្រង**

បន្ថែមលើសពីនេះ និងដោយមិនគិតពីលក្ខខណ្ឌណាមួយនៅទីនេះ លក្ខខណ្ឌទាំងនេះត្រូវបានគ្រប់គ្រង និងត្រូវអនុលោមទៅតាមផ្លូវច្បាប់ បទបញ្ញត្តិ និងការណែនាំជានិច្ចជាកាលដែលចេញដោយធនាគារជាតិនៃកម្ពុជា និងស្ថាប័នពាក់ព័ន្ធនានា ទោះបីជាច្បាប់ បទបញ្ញត្តិ និងការណែនាំទាំងនេះមាន ឬគ្មានអំណាចតាមផ្លូវច្បាប់ក៏ដោយ។ ខ្ញុំ/យើងខ្ញុំយល់ព្រមថា សេវាកម្មនានាដែលកំពុងមាន និងបន្តមាននាពេលបច្ចុប្បន្ន នៅពេលណាក៏ដោយធនាគារផ្តល់អោយខ្ញុំ/យើងខ្ញុំ ត្រូវតែស្របទៅតាមច្បាប់ បទបញ្ញត្តិ និងការណែនាំខាងលើដែលធនាគារបានកំណត់ជាប្រចាំ។

24. **បញ្ជាទូទាត់ដោយស្វ័យប្រវត្តិ ការដកប្រាក់ និងការប្រាក់**

24.1. ការទូរទាត់ឬការផ្ទេរប្រាក់ដែលត្រូវធ្វើ ឬមានប្រសិទ្ធិភាពយោងតាមបញ្ជាទូរទាត់ដោយស្វ័យប្រវត្តិដែលផ្តល់អោយធនាគារនោះតម្រូវអោយគណនីធនាគារត្រូវមានសមតុល្យអប្បបរមាដែលត្រូវទូរទាត់ ឬផ្ទេរដែលត្រូវកំណត់ជាប្រចាំដោយធនាគារ។

24.2. រាល់ការដកប្រាក់ពីគណនីធនាគារណាមួយ ធនាគារអាចតម្រូវអោយបង្ហាញភស្តុតាងនានាដែលអាចបញ្ជាក់ពីអត្តសញ្ញាណ។

24.3. ការប្រាក់លើគណនីធនាគារត្រូវបានបាត់បង់ជូនតាមកម្រិតអត្រាការប្រាក់ និងលក្ខខណ្ឌដូចដែលបានផ្សព្វផ្សាយ ឬជូនដំណឹងជាប្រចាំដោយធនាគារប៉ុណ្ណោះ ហើយការប្រាក់នេះអាចត្រូវបានកំណត់ចំពោះគណនីជាក់លាក់ណាមួយ ឬត្រូវមានសមតុល្យអប្បបរមាមានដែលបានតម្កល់។

25. **ការអនុវត្តលក្ខខណ្ឌ**

លក្ខខណ្ឌទាំងនេះនឹងត្រូវមានអនុវត្តចំពោះភាគីនៅទីនេះ។

26. **ការបម្រុងទុក**

ច្បាប់ទាំងនេះត្រូវស្ថិតនៅក្រោមការបន្ថែម ការកែប្រែ ឬការលុប ឬការអនុវត្តណាមួយដែលកំណត់ជាប្រចាំដោយធនាគារ ហើយខ្ញុំ/យើងខ្ញុំទទួលស្គាល់សិទ្ធិរបស់ធនាគារក្នុងការបន្ថែមការកែប្រែ ឬការលុបចោលពីគ្រាមួយទៅគ្រាមួយ ហើយខ្ញុំ/យើងខ្ញុំនិងអនុវត្តតាមដរាបណាសេចក្តីជូនដំណឹងបានបង្ហាញនៅធនាគារ ឬសាខាណាមួយ ឬផ្ញើរមកខ្ញុំ/យើងខ្ញុំតាមរយៈអាសយដ្ឋានចុះបញ្ជីចុងក្រោយរបស់ខ្ញុំ/យើងខ្ញុំជាមួយធនាគារ ឬតាមទម្រង់ ឬការទំនាក់ទំនងដូចដែលធនាគារជ្រើសរើសយក។

27. **ភាពមិនស្របគ្នា**

ក្នុងករណីដែលមានភាពមិនស្របគ្នាក្នុងការបកស្រាយពាក្យណាមួយនៅក្នុងឯកសារនេះទាំងមូលដែលមានទាំងភាសាខ្មែរ អង់គ្លេស និងចិន ភាសាខ្មែរនិងត្រូវយកមកអនុវត្តជាគោល។

28. **ការបាត់សៀវភៅធនាគារ/កាតអេធីអឹម/វិញ្ញាបនប័ត្រប្រាក់បញ្ញើមានកាលកំណត់**

28.1. ខ្ញុំ/យើងខ្ញុំនឹងរក្សាសៀវភៅធនាគារ/កាតអេធីអឹម/វិញ្ញាបនប័ត្រប្រាក់បញ្ញើមានកាលកំណត់ដោយសុវត្ថិភាព ហើយខ្ញុំ/យើងខ្ញុំរាយការណ៍ជាបន្ទាន់ជាលាយលក្ខខណ៍អក្សរទៅកាន់ធនាគារ ពីការបាត់បង់ ឬពីការលួច។

28.2. សៀវភៅធនាគារនិង/ឬវិញ្ញាបណ្ណប័ត្រប្រាក់បញ្ញើមានការកំណត់ដែលបានបាត់អាចបោះពុម្ពជំនួសម្តងទៀតបានហើយមានហត្ថលេខា និងបោះត្រាលើលិខិតធានាអះអាង ដោយត្រូវបង់កម្រៃសេវា។ សៀវទៅធនាគារ និង/ឬវិញ្ញាបណ្ណប័ត្រប្រាក់បញ្ញើមានការកំណត់ដែលបាត់អាចបោះពុម្ពជំនួសនៅសាខាដែលបើកគណនីតែប៉ុណ្ណោះ។

28.3. ការបោះជំនួសកាតអេធីអឹមដែលបាត់និងត្រូវអនុវត្តតាមលក្ខខណ្ឌនៃការគ្រប់គ្រងប្រតិបត្តិការកាតអេធីអឹម។

29. **ប្រតិបត្តិការនានៃលឪជីថល**

29.1. ខ្ញុំ/យើងខ្ញុំទទួលខុសត្រូវចំពោះការបញ្ចូលនៃព័ត៌មានលម្អិតរបស់អ្នកទទួល និងធានាថាឈ្មោះរបស់អ្នកទទួលដែលបានបង្ហាញគឺជាឈ្មោះអ្នកទទួលផលប្រាដកមែន មុនពេលធ្វើការបញ្ជាក់ប្រតិបត្តិការ។

29.2. ធនាគារអាចជូនដំណឹងដល់ ខ្ញុំ/ពួកយើងអំពីស្ថានភាពនៃប្រតិបត្តិការដែលទទួលបានជោគជ័យ បរាជ័យ ឬត្រូវបានបដិសេធ តាមរយៈបណ្តាញទំនាក់ទំនងណាមួយដែលមានស្រាប របស់ធនាគារ។

29.3. ខ្ញុំ/យើងទទួលស្គាល់ និងយល់ព្រមថាធនាគារមិនមានកាតព្វកិច្ច និងមិនចាត់វិធានការណាមួយដើម្បីផ្ទៀងផ្ទាត់ ឬស្វែងរកការបញ្ជាក់ផ្សេងទៀតពីភាគីណាមួយ ថាតើព័ត៌មានដែលផ្តល់ដោយអ្នកទទួលនោះជាការពិត។ ហើយធនាគារនឹងមិន

ទទួលខុសត្រូវចំពោះការផ្ទេរប្រាក់ទៅកាន់អ្នកទទួលដែលបានចុះឈ្មោះដែលមិនមែនជាអ្នកទទួលដែលមានបំណងនោះទេ។ (ឧទាហរណ៍៖ លេខគណនីខុស ឈ្មោះអ្នកទទួលផលខុស។ល។)

29.4. អនុលោមតាមមាត្រា 29.02 ខាងលើ ខ្ញុំ/ខ្ញុំយល់ព្រមថា នៅពេលដែលប្រតិបត្តិការត្រូវបានបញ្ជាក់រួច វាមិនអាចលុបចោលបានទេ ហើយខ្ញុំ/យើងខ្ញុំនឹងមិនអាចលុបចោល បញ្ឈប់ ឬធ្វើការផ្លាស់ប្តូរណាមួយចំពោះប្រតិបត្តិការនោះបានទេ។

29.5. ដោយមិនមានការរើសអើងចំពោះសិទ្ធិបុគ្គល និងដំណោះស្រាយណាមួយរបស់ធនាគារ។ ធនាគាររក្សាសិទ្ធិក្នុងការបញ្ឈប់ ឬផ្អាកការចូលប្រើប្រាស់ និងប្រើប្រាស់សេវាកម្មរបស់ខ្ញុំ នៅពេលដែលធនាគារពិចារណាថាការប្រើប្រាស់មិនសមរម្យ ការក្លែងបន្លំ ឬគួរឱ្យសង្ស័យកំពុងត្រូវបានធ្វើឡើង។ ខ្ញុំ/យើងត្រូវបានណែនាំឱ្យទាក់ទងធនាគារប្រសិនបើ ខ្ញុំ/យើងជួបប្រទះបញ្ហាណាមួយដែលទាក់ទងនឹងបញ្ហាខាងលើ។

29.6. ការស្តារឡើងវិញនូវការទូទាត់ដែលមានកំហុស និងប្រតិបត្តិការដែលមិនមានការអនុញ្ញាត (រួមទាំងការក្លែងបន្លំ) ដែលធ្វើឡើងពីគណនីរបស់ខ្ញុំ។

29.7. ប្រសិនបើខ្ញុំ/យើងបានធ្វើប្រតិបត្តិការខុស នោះខ្ញុំ/យើងខ្ញុំអាចដាក់សំណើសម្រាប់ការស្តារយកការផ្ទេរប្រាក់ឡើងវិញក្នុងរយៈពេលប្រាំពីរ (7) ថ្ងៃនៃថ្ងៃធ្វើការចាប់ពីថ្ងៃដែលស្នើសុំស្តារប្រតិបត្តិការដែលបានធ្វើខុសត្រូវ ហើយធនាគារនឹងធ្វើការជាមួយធនាគាររបស់អ្នកទទួលរងផលប៉ះពាល់ក្នុង ផ្តល់លក្ខខណ្ឌដូចខាងក្រោមត្រូវបានបំពេញ:

I. មូលនិធិពិតជាត្រូវបានបញ្ចូលខុសទៅក្នុងគណនីរបស់អ្នកទទួលដែលរងផលប៉ះពាល់។
II. ទទួលបានធនាគារដំណើរការឥណទានដោយជោគជ័យ ដែលថវិកាត្រូវបានបញ្ចូលខុសទៅអ្នកទទួលដែលរងផលប៉ះពាល់។
III. សមតុល្យនៅក្នុងគណនីរបស់អ្នកទទួលរងផលប៉ះពាល់គឺគ្រប់គ្រាន់ដើម្បីគ្របដណ្តប់ថវិកាដែលត្រូវបានបញ្ចូលមិនត្រឹមត្រូវ។
IV. ផ្តល់ការជូនដំណឹងដល់អ្នកទទួលរងផលប៉ះពាល់ជាលាយលក្ខណ៍អក្សរទាក់ទងនឹងសំណើរធ្វើការស្តារថវិកាឡើងវិញ។
V. អ្នកទទួលរងផលប៉ះពាល់បរាជ័យក្នុងការបង្កើតសិទ្ធិរបស់ខ្លួនចំពោះថវិកា។
VI. ធនាគាររបស់អ្នកទទួលរងផលប៉ះពាល់ត្រូវទទួលបានពីអ្នកទទួលរងផលប៉ះពាល់នូវការសម្រេចចិត្តក្នុងការផ្តល់ការយល់ព្រមក្នុងការប្រគល់ថវិកាទាំងនោះមកខ្ញុំ/យើងវិញ។

29.8. ធនាគារនឹងខិតខំប្រឹងប្រែងដើម្បីជួយអតិថិជនរបស់ខ្លួនក្នុងការទទួលបានប្រាក់បង្វិលសងសម្រាប់ប្រតិបត្តិការដែលត្រូវបានធ្វើចេញដោយអតិថិជនរបស់ខ្លួនដែលបានធ្វើប្រតិបត្តការណ៍ខុស។ ទោះជាយ៉ាងណាក៏ដោយ ប្រសិនបើធនាគារអស់មធ្យោបាយដែលមានទាំងអស់ ដើម្បីជួយធ្វើការបង្វិលសងនៃការស្នើសុំនោះ អ្នកមិនអាចបន្ត ដាក់ពាក្យបណ្តឹង ឬធ្វើសំណើបន្ថែមណាមួយសម្រាប់ការបង្វិលសងប្រាក់វិញនៃប្រតិបត្តិការដូចគ្នានោះដែរ។

29.9. សម្រាប់ប្រតិបត្តិការដែលមិនត្រូវបានអនុញ្ញាតដោយខ្ញុំ/ពួកយើង ឬក្លែងបន្លំ ធនាគារនឹងទទួលបានរបាយការណ៍ពីខ្ញុំ/ពួកយើង ដោយចោទប្រកាន់ថា ប្រតិបត្តិការគ្មានការអនុញ្ញាត ឬក្លែងបន្លំត្រូវបានធ្វើឡើង ប្រគល់ថវិកាមកខ្ញុំ/ពួកយើងវិញ ដោយផ្តល់លក្ខខណ្ឌដូចខាងក្រោម។ បានជួប៖

I. ធនាគារនឹងធ្វើការស៊ើបអង្កេត និងកំណត់ក្នុងពេលវេលាសមស្រប ប្រសិនបើការទូទាត់ដោយគ្មានការអនុញ្ញាត ឬក្លែងបន្លំបានកើតឡើង។
II. ប្រសិនបើធនាគារការណែនាំអំពីការបង់ប្រាក់ដោយគ្មានការអនុញ្ញាត ឬការក្លែងបន្លំពិតជាបានកើតឡើង ហើយមិនមែនបណ្តាលមកពីខ្ញុំ/ពួកយើងទេ ធនាគារនឹងចាប់ផ្តើមដំណើរការបង្វិលមកវិញ ដែលរាល់ការដកប្រាក់ដែលបានដាក់ចូលក្នុងគណនីរបស់ខ្ញុំ/របស់យើង ដែលកើតឡើងពីការណែនាំអំពីការបង់ប្រាក់ដែលគ្មានការអនុញ្ញាត ឬក្លែងបន្លំ នឹងត្រូវបង្វិលមកវិញ។

29.10. ខ្ញុំ/យើងទទួលស្គាល់ និងយល់ព្រមថា លុះត្រាតែមានការហាមឃាត់យ៉ាងច្បាស់លាស់ដោយច្បាប់ ធនាគារនឹងមិនទទួលខុសត្រូវចំពោះខ្ញុំ/យើង ឬភាគីទីបីណាមួយសម្រាប់ការខាតបង់ ដោយផ្ទាល់ ប្រយោល ឬជាលទ្ធផល បំណុល ការចំណាយ ការខូចខាត ការទាមទារ សកម្មភាព ឬដំណើរការនានាដែលពាក់ព័ន្ធ។ ជាមួយនឹងសេវាកម្មដែលផ្តល់ដោយធនាគារដែលកើតឡើងពី៖

I. ការធ្វេសប្រហែសរបស់ខ្ញុំ ការប្រព្រឹត្តខុស ឬបំពានលើលក្ខខណ្ឌណាមួយនៃលក្ខខណ្ឌទាំងនេះ
II. ការផ្ទេរប្រាក់ដែលមានកំហុសដោយខ្ញុំ/ពួកយើង រួមទាំងការផ្ទេរប្រាក់ទៅអ្នកទទួលខុស ឬភាគីទីបីខុស
III. ការផ្អាក ការបញ្ចប់ ឬការបញ្ឈប់សេវាកម្ម។
IV. របាយការណ៍/សំណើររបស់ខ្ញុំទៅកាន់ធនាគារសម្រាប់ការស្តារឡើងវិញនៃថវិកាមិនត្រូវបានធ្វើឡើងទាន់ពេលវេលា ឬក្នុងពេលវេលាសមរម្យនោះទេ។

29.11. ខ្ញុំ/យើងខ្ញុំនឹងផ្តល់សំណងដល់ធនាគារ និងសម្ព័ន្ធភាពរាល់ការបាត់បង់ ឬការខូចខាតដែលបានទទួលដោយសារតែការទាមទារ ឬសកម្មភាពណាមួយដែលបានធ្វើឡើងប្រឆាំងនឹងធនាគារ និងសាខាដែលបណ្តាលមកពីការធ្វេសប្រហែស និង/ឬការក្លែងបន្លំរបស់ខ្ញុំ។

## GENERAL TERMS AND CONDITIONS ON BANKING ACCOUNTS

The opening of my/our Banking Accounts is governed by the Terms and Conditions contained herein (hereinafter referred to as 'Terms and Conditions'), the Terms and Conditions Governing Banking Accounts and such other specific conditions which may be set forth in the specific application forms and/or brochures, and I/we hereby declare my/our agreement to abide and to be bound by these terms and conditions for the time being in force. These Terms and Conditions are also applicable to electronic Banking Accounts unless otherwise stated.

### 1. Definitions & Interpretation

The expression "Banking account" or "Banking accounts" shall mean each and every account which I/we maintain with the Bank from time to time and, if the context so required shall mean any one of such accounts.

### 2. Deposits

2.01. Every deposit shall be accompanied by a deposit slip or appropriate form issued by the Bank and the instructions contained therein shall be strictly observed.

2.02. Deposit cash into CNY (Chinese Yuan) accounts is not allowed.

2.03. A receipt issued by the Bank is only valid if it is machine validated or acknowledged by an authorized officer of the Bank. I/We are to check that the particulars of transaction(s), where such particulars are furnished to me/us upon completion of transaction(s), are correct before leaving the Bank's premises. If there is any error, I/We shall immediately report it to the Bank.

2.04. Inter branch deposits are allowed subject to charges, if any, as determined by the Bank at its sole and absolute discretion at any time and from time to time.

### 3. Withdrawals

3.01. Withdrawal shall be subject to the available funds in the Banking Accounts.

3.02. Cash withdrawal via Automated Teller machine ("ATM") shall be subject to the terms and conditions governing operations of ATM Cards as may be determined by the Bank.

3.03. Cash withdrawal from CNY (Chinese Yuan) accounts is not allowed. However, cash may be withdrawn in USD after conversion.

3.04. Withdrawals are subject to proof of identity as the Bank may require.

3.05. Inter-branch withdrawals are allowed subject to charges, if any, as determined by the Bank at its sole and absolute discretion at any time and from time to time.

## 4. Interest Rate

4.01. Interest, if any, at such rates as the Bank may at its discretion determine at any time and from time to time.

4.02. Withholding tax, wherever applicable, at the prescribed rate shall be deducted for all interest payments.

## 5. Authorizations and Request

5.01. I/We authorize and request the Bank to honor and comply with all cheques, drafts, orders to pay, bills of exchange and promissory notes expressed to be drawn, signed, accepted, endorsed or made on my/our behalf drawn upon or addressed to or made payable by the Bank whether my account(s) is/are in credit or in debit or may become overdrawn in consequence or otherwise.

5.02. I/We further authorize and request the Bank to honor and comply with any written order to withdraw any or all money on any of my/our account(s) and my/our written instructions to deliver, dispose of or deal with any securities, deeds or documents or other property whatsoever from time to time in the possession of the Bank or my/our account(s) whether by way of security or safe custody or otherwise.

## 6. Banking Charges

6.01. I/We hereby agree that the Bank shall be entitled to charge for any of its services provided to me/us at the rates as determined by the Bank at any time and from time to time. The Bank's charges shall exclude tax of any kind. Such tax, if applicable, shall be borne by me/us. The Bank will be entitled to recover from me/us any tax or penalty that the Bank is required by law to collect. 6.02. All banking charges (together with the tax payable, if applicable) when due shall be debited to my/our banking account(s).

## 7. Change in Particulars

7.01. Any change of address or signatures or other particulars that are recorded with the Bank shall be notified to the Bank in writing.

7.02. All communications including the service of any legal process sent by post to or left at my/our last known address registered with the Bank shall be deemed to have been duly delivered to and received by me/us.

## 8. Closure of Accounts

8.01. I/We acknowledge that my/our Banking Accounts can be closed by me/us in person and I/We undertake to comply with all the Bank's requirements, if any, for the closure of the Banking Accounts.

8.02. The Bank reserves its right to:

(a) close all or any of my/our Banking Accounts for as the Bank deems appropriate by given fourteen (14) days notice of such intention and the Bank shall not be bound to disclose any reasons therefor.

(b) close any of my/our Banking Accounts, in the opinion of the Bank, has been unsatisfactorily conducted. The Bank may impose service charges of closing my/our Banking Accounts.

8.03. Withdrawal of the entire balance in the Banking Accounts shall in no event constitute a closure of accounts.

## 9. Inactive/Dormant Accounts/Unclaimed Monies

9.01. Accounts with no withdrawal and/or deposit for twelve (12) months or more will be deemed as inactive account.

9.02. To activate an Inactive/Dormant account(s), a withdrawal and/or deposit should be performed at the branch where the account was back to normal. Inter branch withdrawals or cheque encashment in inactive accounts will not be permitted.

9.03. The Bank reserves the right to close an Inactive/Dormant Account(s) with zero balance.

9.04. In the event of death, bankruptcy or insanity of me/us, any balance remaining in the credit of my/our Banking Accounts may be paid to my lawful beneficiary subject to compliance with the related legislation rules regulations in force at law and practice.

9.05. The Bank may charge an annual service fee at such amount as the Bank sees fit and appropriate for Inactive/Dormant Account(s) until the remaining balances are sent to the National Bank of Cambodia which shall be accountable thereafter for administering such deposits, pursuant the Law on banking and Financial Institutions.

## 10. Statement of Account

10.01. A statement of the balances on my/our Current Account will only be rendered once a month. Or upon request and the Bank reserves the right to levy a service charge as determined by the Bank from time to time.

10.02. I/We agree to examine my/our Banking Account(s) on receipt of the statement that made available to me through various means or in the case of any account other than current, on any transaction completed and notified the Bank of any errors, irregularities, discrepancies, claims or unauthorized debits or items whether, made, processed or paid as a result of forgery, fraud, lack of authority, negligence or otherwise by any person whatsoever.

10.03. I/We further agree that if I/We fail to advise the Bank in writing on the non-receipt of the statement and obtain the statement from the Bank, or to notify the Bank of any errors, discrepancies, claims, or unauthorized debit or items in the statement within fourteen (14) days from the date of the statement, the Bank's accounts or records shall be conclusive evidence of the transaction entries and balances in such accounts and I/we shall be deemed conclusively to have accepted all matters contained in the statement as true accurate and correct in all respects. Any amendment thereafter of the statement shall be at the sole discretion of the Bank.

## 11. Limitation at Liability

